# របាយការណ៍សង្ខេប
# ស្តីពី
# "វឌ្ឍនភាព និងទិសដៅការងារបន្តរបស់រដ្ឋបាលខេត្តត្បូងឃ្មុំ"
# ក្នុងសន្និសីទសារព័ត៌មាននៅទីស្តីការគណៈរដ្ឋមន្ត្រី
# ឯកឧត្តម សោភ ឡេង ប្រធានក្រុមប្រឹក្សាខេត្តត្បូងឃ្មុំ

(ថ្ងៃទី១៩ ខែមករា ឆ្នាំ២០២១)

-សូមក្រាបថ្វាយបង្គំ សម្តេចព្រះសង្ឃរាជទាំងពីរគណៈ ជាទីគោរពសក្ការៈ

-សូមក្រាបបង្គំទូលថ្វាយ ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងព្រះមហាក្សត្រី **មុនីនាថ សីហនុ** ព្រះវររាជមាតា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត

-សូមគោរព សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត

-សូមគោរព សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាទីគោរពដ៏ខ្ពង់ខ្ពស់

-សូមគោរព **ឯកឧត្តម ផៃ ស៊ីផាន** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រធានអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល ***ជាទីគោរពដ៏ខ្ពង់ខ្ពស់ !***

-ឯកឧត្តម លោកជំទាវ លោក លោកស្រី និងបងប្អូនអ្នកសារព័ត៌មានទាំងអស់ដែលមានវត្តមាននៅក្នុងអង្គសន្និសីទសារព័ត៌មាននាពេលនេះ ***ជាទីមេត្រី !***

-បងប្អូនប្រជាពលរដ្ឋដែលកំពុងទស្សនាការផ្សាយផ្ទាល់ ***ជាទីគោរពស្រលាញ់រាប់អាន!***

ជាបឋម ខ្ញុំសូមថ្លែងអំណរគុណចំពោះអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល ដែលបានរៀបចំសន្និសីទសារព័ត៌មាន ស្តីពី **“វឌ្ឍនភាពមូលដ្ឋានឃុំ/សង្កាត់ និងទិសដៅការងារបន្តរបស់ខេត្តត្បូងឃ្មុំ”** និងសូមអរគុណចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី និងបងប្អូនអ្នកសារព័ត៌មានទាំងអស់ដែលបានចូលរួមក្នុងសន្និសីទនេះ។

ក្នុងនាម ក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ និងប្រជាពលរដ្ឋទាំងអស់ នៅក្នុងខេត្តត្បូងឃ្មុំទាំងមូល ខ្ញុំសូមយកឱកាសនេះសម្តែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលនាំសន្តិភាពជូនប្រទេស និងពលរដ្ឋកម្ពុជា **“សូមអរគុណសន្តិភាព”** ដែលធ្វើ

ឲ្យប្រទេសជាតិមានសុខសន្តិភាព ស្ថេរភាពនយោបាយ សុវត្ថិភាព សន្តិសុខ និងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមជាតិទាំងមូល។

ដោយអនុវត្តតាមគោលនយោបាយដឹកនាំដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាលដែលមាន សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដោយមានកម្មវិធីនយោបាយ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលជាគោល មានផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ និងផែនការវិនិយោគ៣ឆ្នាំរំកិល ដែលបានអនុម័តដោយក្រុមប្រឹក្សាខេត្តជាត្រីស័យ រដ្ឋបាលខេត្តត្បូងឃ្មុំ សម្រេចបាននូវសមិទ្ធផលការងារសំខាន់ៗ ដូចខាងក្រោម ៖

## ❖ ភូមិសាស្ត្រខេត្តត្បូងឃ្មុំ

ខេត្តត្បូងឃ្មុំ លាតសន្ធឹងតាមបណ្តោយទន្លេមេគង្គ និងជាខេត្តជាប់ព្រំដែន មានព្រំប្រទល់៖

- ខាងលិចទល់នឹង ខេត្តកំពង់ចាម
- ខាងកើតទល់នឹង ខេត្តតៃនិញ និងខេត្តប៊ិញភឿក ប្រទេសវៀតណាម
- ខាងជើងទល់នឹង ខេត្តក្រចេះ
- ខាងត្បូងទល់នឹង ខេត្តព្រៃវែង និងខេត្តតៃនិញ ប្រទេសវៀតណាម។
- ផ្ទៃដីសរុប មានទំហំ **៥ ២៥០,៥២**គ.ម$^{២}$
- មាន ក្រុង១ និងស្រុក៦ ឃុំ-សង្កាត់ ចំនួន ៦៤ និងភូមិ ចំនួន ៨៧៣ភូមិ។
- **ប្រជាពលរដ្ឋ**សរុប ចំនួន ៨៦៤ ៣១៩នាក់ ស្រី ៤៣៩ ៥៤៤នាក់ គិតជាគ្រួសារ ស្មើនឹង ១៩៦ ០៦៥គ្រួសារ អ្នកដែលមានអាយុ ១៨ឆ្នាំឡើង ៤៤៨.៥៨៣នាក់។

## ❖ ការងារក្រុមប្រឹក្សា

ផ្អែកតាមគោលនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ របស់រាជរដ្ឋាភិបាលកម្ពុជា បានរៀបចំច្បាប់រៀបចំអង្គការ ដែលជាមូលដ្ឋានគតិយុត្តិសម្រាប់កិច្ចកំណែទម្រង់រដ្ឋបាលតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងបានបង្កើតឱ្យមានក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ តាមរយៈការបោះឆ្នោតអសកល។ ក្រុមប្រឹក្សា ត្រូវមានគណនេយ្យភាពជាចម្បង និងដោយផ្ទាល់ចំពោះប្រជាពលរដ្ឋ សំដៅធានាដល់ការបង្កើននូវតម្លាភាព ជំរុញឱ្យមានការចូលរួមរបស់ប្រជាពលរដ្ឋ យកចិត្តទុកដាក់សំខាន់លើតម្រូវការរបស់ប្រជាពលរដ្ឋ ក្នុងការធ្វើសេចក្តីសម្រេចចិត្ត វិភាជន៍ធនធាន ផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន។

ខេត្តត្បូងឃ្មុំ មានសមាជិកក្រុមប្រឹក្សាដូចខាងក្រោម៖

- សមាជិកក្រុមប្រឹក្សាខេត្ត មានចំនួន ២៥ នាក់ ស្រី ៤នាក់ (បោះឆ្នោតអសកល)
- សមាជិកក្រុមប្រឹក្សាក្រុង-ស្រុក មានចំនួន ១៣៧ នាក់ (បោះឆ្នោតអសកល)
- សមាជិកក្រុមប្រឹក្សាឃុំសង្កាត់ មានចំនួន ៥៣៦ នាក់ (បោះឆ្នោតសកល)

ក្នុងឆ្នាំ២០២០ ក្រុមប្រឹក្សាខេត្តបានចូលរួមក្នុងកម្មវិធីផ្សេងៗសរុបចំនួន ២៦លើក ថែមទាំងបានបើកកិច្ចប្រជុំរបស់ខ្លួន និងគណៈកម្មាធិការនានា ៣៩លើក ក្នុងនោះកិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សា ១២លើក គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ១លើក គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ១២លើក និងកិច្ចប្រជុំគណៈកម្មាធិកាលទ្ធកម្ម ១៤លើក។ ការរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់តាមក្រុង-ស្រុក លើកទី៣ អាណត្តិទី៣ តាមបណ្ដាក្រុង-ស្រុកទាំង៧ មានអ្នកចូលរួមសរុបចំនួន **១,៦៥១**នាក់ ស្រី **៤៤៥**នាក់។ ជាលទ្ធផល ទទួលបានសំណូមពរ និងដំណោះស្រាយសរុបចំនួន **១០៤** ក្នុងនោះ បកស្រាយបំភ្លឺ និងដោះស្រាយរួចចំនួន **១០៣** និងនៅសល់សំណូមពរចំនួន **០១** មិនទាន់ដោះស្រាយ។

### សមិទ្ធផលសំខាន់ៗ សម្រេចបានក្នុងឆ្នាំ២០២០ របស់ខេត្ត

ដោយអនុវត្តតាមគោលនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ នីតិកាលទី៦ របស់រាជរដ្ឋាភិបាលកម្ពុជា ក្រុមប្រឹក្សាខេត្ត បានអនុម័តក្របខ័ណ្ឌអភិវឌ្ឍន៍ខេត្ត ស្របតាមផែនការអភិវឌ្ឍន៍៥ឆ្នាំ និងផែនការវិនិយោគ៣ឆ្នាំរំកិល សរុបចំនួន**១១៦**គម្រោង ក្នុងនោះ គម្រោងវិនិយោគរបស់រដ្ឋបាលខេត្តចំនួន**១៣**គម្រោង ។ គម្រោងមូលនិធិក្រុង-ស្រុក ចំនួន**២២**គម្រោង និងគម្រោងមូលនិធិឃុំ/សង្កាត់ចំនួន**៨១**គម្រោង ។

សមិទ្ធផលដែលសម្រេចបាន និងកំពុងដំណើរការសាងសង់រួមមាន៖ មន្ទីរពេទ្យខេត្តត្បូងឃ្មុំសាងសង់សម្រាចបាន**៩០**% ស្ពានស្ទឹងត្រង់-ក្រូចឆ្មារ សាងសង់បាន **៩៥**% ហើយតាមការគ្រោងទុកនឹងដាក់អោយដំណើរការនៅខែមីនា ឆ្នាំ២០២១ខាងមុខនេះ ការសាងសង់អគារមន្ទីរពេទ្យបង្អែកស្រុកក្រូចឆ្មារ ដែលមានទំហំ៨១,៤២មx១៥ម កម្ពស់៤ជាន់ សម្រេចបានប្រមាណ**២០**%។ ការសាងសង់អគារមន្ទីរពេទ្យបង្អែកស្រុកតំបែរ ទំហំ១៥មx៣៦ម កម្ពស់០៣ជាន់ សម្រេចបានប្រមាណ**៤០**%។ ទន្ទឹមនេះ ការអភិវឌ្ឍន៍តំបន់ទីរួមខេត្តត្បូងឃ្មុំ បាននឹងកំពុងដំណើរការស្ថាបនា សាងសង់ កែលម្អជាបន្តបន្ទាប់ដើម្បីលើកកម្ពស់សោភ័ណភាព បរិស្ថាន អនាម័យកែប្រែមុខមាត់ស្រស់បំព្រងរបស់ខេត្តដោយបានធ្វើការរៀបចំ៖

-បណ្ដាញលូមេក្រោមតួផ្លូវ “គ” ខ្សែទី១ ប្រវែង **១,៤៥០**ម៉ែត្រ តភ្ជាប់ពីផ្លូវជាតិលេខ៧៣ ទៅផ្លូវ “ខ១”។

-បណ្តាញលូមេក្រោម តួផ្លូវប្របផ្លូវជាតិ លេខ ៧៣ ប្រវែង **១,៥៧០**ម៉ែត្រ តភ្ជាប់ពីផ្លូវ “ក” (ចេញពីតំបន់អគារស្នាក់នៅមន្ត្រីរាជការ) ទៅ កាន់ផ្លូវ “គ” ខ្សែទី១។

-ផ្លូវក្រាលគ្រួសក្រហមថ្មី (ទទឹង ២៤,៥ ម៉ែត្រ) ប្រវែង **១,០៤០**ម៉ែត្រ តភ្ជាប់ពីផ្លូវ “ឃ” ទៅកាន់ផ្លូវ “គ” ខ្សែទី១។

-បណ្តាញលូមេរំដោះទឹកភ្លៀង (ប្រភេទលូប្រអប់បេតុងអាម៉េ ទំហំ ៣,៦ម៉ែត្រ x២,៦ ម៉ែត្រ) និងលូទឹកកខ្វក់ ប្រវែង **៤៨០**ម៉ែត្រ តភ្ជាប់ពីផ្លូវ “ក” (មុខសាកលវិទ្យាល័យហេងសំរិន ត្បូងឃ្មុំ) កាត់ផ្លូវជាតិលេខ៧៣ ទៅកាន់ស្ថានីយសម្អាតទឹកកខ្វក់ទី២។

-ផ្លូវកៅស៊ូប្រវែង **៥,៥០០**ម៉ែត្រ ពីផ្លូវភ្លោះមាត់ទន្លេ កាត់មុខស្នងការនគរបាលខេត្ត ហើយស្របនឹងផ្លូវជាតិលេខ៧៣ ដល់ផ្លូវភ្លោះក្រោយសាកលវិទ្យាល័យ ហេង សំរិន ត្បូងឃ្មុំ។

-ស្ថាបនាស្ថានីយ៍ និងអាងប្រព្រឹត្តកម្មទឹកកខ្វក់ ចំនួន ២ កន្លែង៖ ទៅខាងលិចផ្លូវជាតិលេខ ៧ និងខាងកើតផ្លូវជាតិលេខ៧៣ (មុខសាកលវិទ្យាល័យ ហេងសំរិន ត្បូងឃ្មុំ)។

-រៀបចំការ៉ូឡាសម្រាប់ថ្មើរជើង សួនលម្អសាធារណៈ ភ្លើងបំភ្លឺសាធារណៈ បណ្តាញលូបង្កប់ខ្សែភ្លើង ខ្សែបណ្តាញលូបង្កប់ខ្សែភ្លើង និងបណ្តាញទូរគមនាគមន៍ នៅលើផ្លូវដែលបានស្ថាបនារួចហើយ ក្នុងតំបន់រដ្ឋបាលខេត្ត។ សាងសង់បណ្តាញលូមេក្រោមដី បណ្តាញលូរំដោះទឹកភ្លៀង និងលូទឹកកខ្វក់ ការសាងសង់ផ្លូវប្រភេទ(ឃ) សាងសង់វេទិកា បន្ទប់សាធារណៈ និងហេដ្ឋារចនាសម្ព័ន្ធខាងក្រៅសាធារណៈ សម្រេចបានប្រមាណ**៥០**%។

-សាងសង់អគារស្នាក់នៅមន្ត្រីរាជការបន្ថែមចំនួន ៦អគារ សម្រេចបានប្រមាណ៦០%។

-ជាមួយនឹងការងារអភិវឌ្ឍន៍តំបន់ទីរួមខេត្ត ការងារចុះបញ្ជីអត្រានុកូលដ្ឋានគ្រប់ប្រភេទជូនប្រជាពលរដ្ឋសម្រេចបានចំនួន **១៩,៨៥៣**នាក់ ស្រី **១០,៨៨៣**នាក់ ក្នុងនោះ បញ្ជីកំណើតចំនួន ៦.៧៥៤នាក់ ស្រី ៣.៥៦១នាក់ បញ្ជីបញ្ជាក់កំណើតចំនួន **៩,០១២**នាក់ ស្រី **៥,៣៧០**នាក់ បញ្ជីមរណភាព **១,១៥៩**នាក់ ស្រី **៤៨៨**នាក់។

**-ការងារគ្រប់គ្រងដីធ្លី និងសំណង់៖** ករណីវិវាទដីធ្លីចំនួន**៩៣លើក** ក្នុងនោះ បានដោះស្រាយបញ្ចប់ **៣៣**ករណី ប្រានចោល**១៨ករណី** ដកពាក្យបណ្តឹង**១៦ករណី** បញ្ជូនរឿង**០៨ករណី** កំពុងបន្តដោះស្រាយ**១៨ករណី។** ការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធចំនួន**៣៣,៨៤៧**ក្បាលដី ចែកប័ណ្ណកម្មសិទ្ធិរួចចំនួន **៣៣,០០០**ប័ណ្ណ ការចុះបញ្ជីមានលក្ខណៈដាច់ដោយដុំ (អង្កេតវាស់វែងចំនួន**១៦៩**ក្បាលដី ចេញប័ណ្ណចំនួន **១៥៤**ប័ណ្ណ)។

-ដោយឡែក ការថែទាំផ្លូវថ្នល់ជាប្រចាំលើកំណាត់ផ្លូវជាតិ និងផ្លូវខេត្តរួមមាន៖ ផ្លូវជាតិលេខ ៧ ផ្លូវជាតិលេខ៨ ផ្លូវជាតិលេខ៧២ ផ្លូវជាតិលេខ៧៣ ផ្លូវលេខ៣៧០អា ផ្លូវលេខ៣៧០បេ ផ្លូវ

លេខ៣៧០សេ ផ្លូវលេខ៣៧១ ផ្លូវលេខ៣៧១បេ ផ្លូវលេខ៣១១៧ ផ្លូវលេខ៣៧២អា និងផ្លូវ៣៧៣ សរុបប្រវែង **២២៣,៩៦គ.ម** សម្រេចបានប្រមាណ ៩០%។

- ការជួសជុលខួប នៃការងារជួសជុលកំណាត់ផ្លូវខេត្តលេខ៣៧១ សរុបប្រវែង **២,៩០០** ម៉ែត្រ សម្រេច ៥៣% ។

- សាងសង់ផ្លូវក្រាលកៅស៊ូពីរជាន់ (DBST) ចំនួន០២ខ្សែ មានប្រវែងសរុប **២៤,000** ម៉ែត្រ សម្រេច បាន ៩០%។

- បានចុះពិនិត្យការងារជួសជុលលក្ខណៈខួបក្រាលក្រួសក្រហម ចំនួន០៥ខ្សែ ប្រវែងសរុប ៣៦.៣០០ម៉ែត្រ គម្រោងថែទាំប្រវែង **២០.៨០០**ម៉ែត្រ និងលូមូល ១៤កន្លែង។ គម្រោងមន្ទីរអភិវឌ្ឍជនបទខេត្ត ១ខ្សែ ប្រវែងសរុប**៣.៥០០**ម៉ែត្រ និងគម្រោង (TRIP) ចំនួន០១ខ្សែ ប្រវែងសរុប**១២.000**ម៉ែត្រ សម្រេចបាន ៩០%។

- ចុះពិនិត្យការងារជួសជុលក្ខណៈប្រចាំ ក្រាលក្រួសក្រហមចំនួន១០ខ្សែ ប្រវែងសរុប **១០៤.000** ម៉ែត្រ សម្រេចបាន ៩០%។

- ចុះពិនិត្យការងារសាងសង់ផ្លូវគម្រោងសាច់ប្រាក់ពលកម្ម សម្រាប់អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជនបទ និងគាំទ្រកសិករ ចំនួន ០៦អនុគម្រោង ប្រវែង **៤,០១០**ម៉ែត្រ។

-សាងសង់ផ្លូវក្រាលកៅស៊ូ និងបេតុងរបស់គម្រោងកែលម្អផ្លូវជនបទជំហាន**III** (ADB) ចំនួន ២ខ្សែ មានប្រវែង**២៤,000**ម៉ែត្រ និងកំពុងសិក្សាផ្លូវសាងសង់ថ្មីក្រាលកៅស៊ូចំនួន០៣ខ្សែបន្ថែមទៀត មានប្រវែងសរុប **៣៦,៥០០**ម៉ែត្រ។

ការធ្វើកំណែទម្រង់ក្នុងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋប្រកបដោយ តម្លាភាព គណនេយ្យភាព និងបរិយាបន្ន ជាពិសេស គឺងាយស្រួលមិនសាំញ៉ាំ ឆាប់រហ័ស និងទាន់ពេលវេលា តាមរយៈយន្តការច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋខេត្ត។ អង្គភាពច្រកចេញចូលតែមួយ មានតួនាទី ភារកិច្ច ជាអ្នកផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ ដោយឡែក ការិយាល័យប្រជាពលរដ្ឋ ជាអ្នកតាមដានឃ្លាំមើល លើការងារផ្តល់សេវា និងរាយការណ៍ដោយផ្ទាល់ជូនក្រុមប្រឹក្សា ដើម្បីដោះស្រាយជូនប្រជាពលរដ្ឋ។

ចំពោះការផ្តល់សេវារបស់អង្គភាពច្រកចេញចូលតែមួយខេត្ត ទទួលបានសេវាសរុបចំនួន **១៦, ៣២៦** សេវា ដែលសរុបជាទឹកប្រាក់ចំនួនប្រមាណ **១,៩៦៣**លានរៀល លើវិស័យជំនាញចំនួន១២ បន្ថែមលើសេវារដ្ឋបាលដែលផ្តល់ដោយរដ្ឋបាលខេត្ត។ ក្រៅពីនេះ រដ្ឋបាលក្រុងស្រុកទាំង៧ មានក្រុង-ស្រុកចំនួន៣ ហើយដែលមានការិយាល័យច្រកចេញចូលតែមួយ រួមមាន៖ ក្រុងសួង ស្រុកត្បូងឃ្មុំ និងស្រុកមេមត់ ដោយសម្រេចបានចំនួន **៥៤ ៦៩៦**សេវា សរុបជាទឹកប្រាក់ចំនួនប្រមាណ **១១៥**លានរៀល។

## ការងារប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩

ដោយអនុវត្តតាមវិធានណែនាំសុវត្ថិភាពរបស់របស់រាជរដ្ឋាភិបាល និងក្រសួងសុខាភិបាល រដ្ឋបាលខេត្ត ក្រុង ស្រុក និងទទួលបានការគាំទ្រពីក្រុមការងាររាជរដ្ឋាភិបាល បានបើកយុទ្ធនាការប្រយុទ្ធប្រឆាំងនឹងការរីករាលដាលនៃជំងឺកូវីដ-១៩ ក្នុងសហគមន៍ប្រកបដោយជោគជ័យ ក្នុងនោះ ការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និងវេបសាយក្នុងខេត្ត សរុបចំនួន**៦៥**អត្ថបទ បិទផ្សាយផ្ទាំងរូបភាពសរុបចំនួន**៥៩**,**១២៧**សន្លឹក ចាក់មេក្រូចំនួន**៤២**លើក តាមបណ្តាញសង្គមចំនួន**១១**លើក។ ចំពោះការយកសំណាកទៅពិនិត្យសរុបចំនួន**៥**,**៦១៦**នាក់ អវិជ្ជមានចំនួន**៥**,**៥៨២**នាក់ និង វិជ្ជមានចំនួន**១៣**នាក់ បានព្យាបាលជាសះស្បើយទាំងអស់ ព្រមទាំងបន្តយកចិត្តទុកដាក់អនុវត្តនូវវិធានការចត្តាឡីស័ក ដល់បងប្អូនប្រជាពលរដ្ឋដែលត្រឡប់មកពីក្រៅប្រទេសយ៉ាងខ្ជាប់ខ្ជួន។

សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី ក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានខេត្ត និង ថ្នាក់ដឹកនាំ មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធក្នុងខេត្ត បានបរិច្ចាគថវិកា ដើម្បីទ្រទ្រង់មូលនិធិរបស់រដ្ឋបាលខេត្ត ក្នុងការប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ សរុបចំនួន**១៧៤**,**៤៣០**,**០០០៛ និង៥២៤៣$**។ ថ្នាក់ដឹកនាំ មន្ត្រីរាជការ កងកម្លាំង ប្រដាប់អាវុធ និងប្រជាពលរដ្ឋទូទាំងខេត្ត បានចូលរួមបរិច្ចាគថវិកា ជូនរាជរដ្ឋាភិបាលកម្ពុជា ក្នុងការទិញវ៉ាក់សាំងការពារជំងឺកូវី-១៩ សរុបទឹកប្រាក់ចំនួន**២៦៧**,**៨២០**,**៥០០៛** និង **៣**,**៥៦៥$** ក្នុងនោះ តាមរយៈ សហភាពសហព័ន្ធយុវជនកម្ពុជាខេត្ត ទឹកប្រាក់ចំនួន**៤៦**,**៥៨០**,**៥០០៛** និង **១៩០$។**

ជារួម ក្រោមការដឹកនាំរបស់រដ្ឋបាលខេត្តត្បូងឃ្មុំ ដែលមានក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត រួមនឹងការគាំទ្រជាចាំបាច់របស់ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តត្បូងឃ្មុំ ដែលដឹកនាំដោយ **ឯកឧត្តម ជា សុផារ៉ា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់** បានធ្វើឲ្យខេត្តត្បូងឃ្មុំ មានការអភិវឌ្ឍរីកចម្រើនលើគ្រប់វិស័យ។ ក្នុងនោះ ការងារគ្រប់គ្រងរដ្ឋបាល ការរក្សាសន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាពសាធារណៈ ការងារកំណែទម្រង់ប្រព័ន្ធអភិបាលកិច្ច ការងារផ្តល់សេវាសាធារណៈ ការងារគ្រប់គ្រងព្រំដែន និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ការអភិវឌ្ឍសមត្ថភាព ផ្នែកសេដ្ឋកិច្ច ផ្នែកសង្គមកិច្ច ការអភិវឌ្ឍវិស័យឯកជន វិស័យការងារ និងវិស័យបណ្តុះបណ្តាល ការគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន និងគ្រោះមហន្តរាយ ការគ្រប់គ្រងដីសាធារណៈរបស់រដ្ឋ ការដោះស្រាយទំនាស់ដីធ្លី ក៏កំពុងត្រូវបានធានា និងមានការអភិវឌ្ឍរីកចម្រើនគួរឲ្យកត់សម្គាល់ដែលបានរួមចំណែកយ៉ាងសំខាន់ដល់ខេត្ត ទាំងមូល មានការប្រែមុខមាត់ថ្មី ព្រមទាំងបានលើកកម្ពស់ស្ថានភាព និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋមានភាពប្រសើរឡើង ពីមួយឆ្នាំទៅមួយឆ្នាំ ។

ក្នុងនាមរដ្ឋបាលខេត្ត សូមប្តេជ្ញាថា នឹងខិតខំបន្តអនុវត្តនូវគោលនយោបាយ និងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០១៩-២០២៣ ដែលបានរួមចំណែកយ៉ាងធំធេង ក្នុងការថែរក្សាបាននូវសន្តិសុខ ស្ថេរភាពនយោបាយនិងសង្គម និងបង្កើនគុណភាពនៃការផ្តល់សេវាប្រកបដោយគណនេយ្យភាព តម្លាភាព មានការអភិវឌ្ឍន៍ប្រកបដោយចីរភាព បង្កើតបាននូវបុរេលក្ខខណ្ឌចាំបាច់ និងបរិស្ថានអនុគ្រោះ សម្រាប់ការប្រែក្លាយខ្លួនឲ្យទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។ ជាពិសេស សូមដាក់ចេញនូវវិធានការចាំបាច់ និងទិសដៅអាទិភាពមួយចំនួនដូចខាងក្រោម៖

-ជំរុញការអនុវត្តគោលនយោបាយ អភិវឌ្ឍន៍ជាតិ ស្របតាមផែនការយុទ្ធសាស្ត្រចតុកោណដំណាក់ ៤ អាណត្តិទី៦។

-បន្តពង្រឹងការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម និងអនុវត្តគោលនយោបាយភូមិ-ឃុំ មានសុវត្ថិភាព នៅគ្រប់ទីកន្លែង និងគ្រប់ពេលវេលា ។

-បន្តរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ របស់ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ស្រុក ដើម្បីប្រមូល បញ្ហាប្រឈម សំណូមពរ ដើម្បីធ្វើការដោះស្រាយជូនប្រជាពលរដ្ឋ។

-បន្តលើកគម្រោង រៀបចំ សាងសង់អភិវឌ្ឍន៍តំបន់ទីរួមខេត្ត សំដៅកែលំអ លើកកម្ពស់សោភ័ណភាពទីរួមខេត្ត។

-លើកកម្ពស់ការងារបណ្តុះបណ្តាល បច្ចេកទេសថ្មីៗលើវិស័យកសិកម្ម ដែលធន់ជាមួយអាកាសធាតុប្រែប្រួល និងពង្រឹងសមត្ថភាពសហគមន៍កសិកម្ម ក្នុងការផលិតកម្មកសិកម្ម ឱ្យស្របតាមផែនការនិងផ្សារភ្ជាប់ជាមួយទីផ្សារ។

-បន្តកិច្ចសហប្រតិបត្តិការការជាមួយ បណ្តាប្រទេសជិតខាង សំដៅការកសាងតំបន់ព្រំដែនប្រកបដោយសន្តិភាព និងការអភិវឌ្ឍន៍។

-ខិតខំទាក់ទាញក្រុមហ៊ុនវិនិយោគនានា ដើម្បីពិនិត្យលទ្ធភាពក្នុងការបោះទុនវិនិយោគ បង្កើតការងារនៅមូលដ្ឋាន និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។

-ជំរុញការតបណ្តាញអគ្គិសនីដែលនៅសេសសល់ និងបណ្តាញទឹកស្អាត ។

-បង្កើនគុណភាពអប់រំនៅតាមមូលដ្ឋាន និងលើកកម្ពស់ឱ្យមានការចូលរួមពីប្រជាពលរដ្ឋ លើការងារទុកដាក់ និងគ្រប់គ្រងសំរាម។

-បន្តថែរក្សាការពារអភិរក្សតំបន់ព្រៃលិចទឹក បឹងធម្មជាតិ នៅស្រុកក្រូចឆ្មារ ស្រុកត្បូងឃ្មុំ និងក្រុងស្រុកដទៃទៀត។

-បន្តការទប់ប្រាំងទន្លេ និងការស្តារ សាងសង់ប្រព័ន្ធធារាសាស្ត្រ។

-បង្កើនប្រសិទ្ធភាពក្នុងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ។
-ការលំអសួនច្បារនៅក្រុងសួង។
-អភិរក្សទីតាំងតំបន់ប្រវត្តិទុំ-ទាវ។
-និងបន្តដោះស្រាយកិច្ចការងារដទៃទៀត ដែលនៅសេសសល់។

ជាទីបញ្ចប់ ខ្ញុំសូមបួងសួងប្រសិទ្ធិពរជ័យ សិរីមង្គល វិបុលសុខគ្រប់ប្រការ និង សូមគោរពជូនពរ សម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី និងអង្គសន្និសីទទាំងមូល សមប្រកបនឹងពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាត ឡើយ ។ សូមអរគុណ!